ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

## បទបញ្ជាផ្ទៃក្នុងសាលសវនាការសម្រាប់ថ្ងៃសវនាការ

ដើម្បីរក្សានូវសណ្តាប់ធ្នាប់ របៀបរៀបរយ សន្តិសុខ និងដំណើរការល្អក្នុងពេលសវនាការប្រធានអង្គជំនុំជម្រះសាលាដំបូង សម្រេចដាក់ចេញនូវបទបញ្ជាផ្ទៃក្នុងសាលសវនាការក្នុងអំឡុងពេលសវនាការដូចខាងក្រោម ៖

១. អ្នកដែលមានបំណងចូលរួមក្នុងសាលសវនាការទាំងអស់ ត្រូវមានវត្តមានក្នុងសាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាឱ្យបានមុនម៉ោង ៨.៣០ នាទីព្រឹក និងមុនម៉ោង ១.៣០ រសៀល។

២. អ្នកចូលរួមក្នុងសាលសវនាការត្រូវមានអាកប្បកិរិយាថ្លៃថ្នូរ សមរម្យ ជានិច្ច។ អ្នកចូលរួមត្រូវស្លៀកពាក់សម្លៀកបំពាក់ឱ្យបានសមរម្យ។ អ្នកចូលរួមមិនត្រូវស្លៀកពាក់សម្លៀកបំពាក់ណាដែលមានពាក្យស្លោកបង្ហាញអំពីការគាំទ្រដល់ភាគីណាមួយនៃកិច្ចដំណើរការនីតិវិធី ឬពាក្យស្លោកដែលមានលក្ខណៈវាយប្រហារ។ ហាមយកបដាផ្សេងៗចូលក្នុងសាលសវនាការ។

៣. ហាមយកម៉ាស៊ីនថតរូបភាព ម៉ាស៊ីនថតវីដេអូ ឧបករណ៍ថតសម្លេង និងឧបករណ៍បំពងសម្លេងគ្រប់ប្រភេទចូលក្នុងសាលសវនាការ លើកលែងតែមានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង។

៤. ហាមជក់បារី ឬ យកចំណីអាហារ ភេសជ្ជៈគ្រប់ប្រភេទចូលក្នុងសាលសវនាការ។

៥. ហាមយកអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវ គ្រឿងបង្កចំហេះគ្រប់ប្រភេទចូលក្នុងសាលសវនាការ លើកលែងតែភ្នាក់ងារសន្តិសុខដែលមានសមត្ថកិច្ច។

៦. ហាមប្រើប្រាស់ទូរសព្ទ័គ្រប់ប្រភេទក្នុងសាលសវនាការ។ហាមថតរូបភាព ឬ ថតសម្លេង តាមគ្រប់មធ្យោបាយ លើកលែងតែមានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង។

៧. ហាមប្តូរកន្លែងអង្គុយ ឬ ដើររបេះរបូតក្នុងសាលសវនាការ។

៨. ហាមទះដៃ ឬស្រែកជ័យឃោស ឬស្រែកឡូឡា ឬការធ្វើឱ្យមានសម្លេងខ្លាំងនាំឱ្យរំខានដល់ដំណើរការសវនាការ។

៩. ហាមដើរចេញចូលដោយអនាធិបតេយ្យនៅពេលសវនាការ ។ ការចេញចូលត្រូវមានការអនុញ្ញាតពីកម្លាំងសន្តិសុខរក្សាសណ្តាប់ធ្នាប់ក្នុងសាលសវនាការ។

១០. ហាមកុមារមានអាយុតិចជាង១៦ឆ្នាំចូលក្នុងសាលសវនាការ ។ កុមារដែលមានអាយុចាប់ពី១៦ឆ្នាំ ដល់ក្រោម១៨ឆ្នាំ អាចចូលក្នុងសាលសវនាការបានប្រសិនបើ គាត់មកជាមួយឪពុកឬម្តាយ ឬអ្នកអាណាព្យាបាល លើកលែងតែកុមារណាដែលត្រូវចូលរួមក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណី ឬជាសាក្សី ។

១១. ក្នុងករណីមានបុគ្គលប្រព្រឹត្តល្មើសនឹងបទបញ្ជាផ្ទៃក្នុងនេះ ប្រធានអង្គជំនុំជម្រះសាលាដំបូង នឹងចាត់វិធានការដើម្បីរារាំង ឬទប់ស្កាត់ភ្លាមតាមករណីសមស្រប ផ្អែកតាមវិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និង បទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជាជាធរមាន ។

ភ្នំពេញ ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០០៩

**ប្រធានអង្គជំនុំជម្រះសាលាដំបូង**

TRIAL CHAMBER CHAMBRE DE PREMIÈRE INSTANCE E C C C • C E T C

និល ~ ណុន